ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៦៧
ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧
សាលដីកា
លេខ ៥៤ "II"
ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០

ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. ឯកឧត្តម [redacted] ជាប្រធាន

២. លោក [redacted] ជាចៅក្រម

៣. លោក [redacted] ជាចៅក្រម

៤. លោក [redacted] ជាចៅក្រម

៥. លោកស្រី [redacted] ជាចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ២៨៤ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ឈ៉ាន់ និងឈ្មោះ [redacted] ឆាវី ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៥៨ "ក្រIV ទល" ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ដែលមាន ៖

-បុគ្គលប្ដឹងសាទុក្ខ ៖

១.ជនជាប់ចោទឈ្មោះ [redacted] ឈ៉ាន់ ភេទប្រុស កើតឆ្នាំ១៩៧៤ សញ្ជាតិខ្មែរ មុខរបរគក់ជេរម៉ូតូ និងរត់ម៉ូតូឌុប ទីកន្លែងកំណើតភូមិ [redacted] ខេត្តកណ្ដាល មានទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន ០២ នាក់។ ទោសពីមុនគ្មាន។

Scanned with CamScanner

២.ជនជាប់ចោទឈ្មោះ [redacted] ឆារី ភេទប្រុស កើតឆ្នាំ១៩៨៥ សញ្ជាតិខ្មែរ មុខរបរតម្លុំតូប ទីកន្លែងកំណើតភូមិ [redacted] រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] "ៈ" ម្តាយឈ្មោះ [redacted] "ៈ" នៅលីវ។ ទោសពីមុនគ្មាន។

-ជាប់ចោទពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចភូមិ ១ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង ភេទស្រី កើតឆ្នាំ១៩៧៣ សញ្ជាតិខ្មែរ មុខរបរលក់បាយលក់កាហ្វេ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] រាជធានីភ្នំពេញ។ ប្តីឈ្មោះ [redacted] មានកូន ០២នាក់។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង ០៥ និង៣០ នាទីយប់ ឈ្មោះ [redacted] ធី និងប្រពន្ធឈ្មោះ [redacted] ហៀង ព្រមទាំងកូនឈ្មោះ [redacted] ផល្លា បាននាំគ្នារៀបចំកន្លែងលក់បាយ និងកាហ្វេនៅផ្ទះដូចសព្វដងៈស្រាប់តែឈ្មោះ [redacted] ឈាវ៉ាន់ និងប្រពន្ធឈ្មោះ [redacted] វណ្ណៈ បានមករករឿងឈ្មោះ [redacted] ធី ឱ្យលើកគ្រែចេញព្រោះៈទើសផ្លូវគេចេញចូល ប៉ុន្តែឈ្មោះ [redacted] ធី មិនបានលើកចេញទេក៏ត្រូវឈ្មោះ [redacted] ឈាវ៉ាន់ និងប្រពន្ធដាក់គ្រែនោះចេញ បន្ទាប់មកក៏មានទំនាស់ពាក្យសម្តីកើតឡើង។ ពេលនោះឈ្មោះ [redacted] ឈៀង ដែលត្រូវជាឪពុកឈ្មោះ [redacted] ឈាវ៉ាន់ បានមកសួរនាំពី មូលហេតុនៃទំនាស់បណ្តាលឱ្យមានការប្រកែកពាក្យសម្តីកាន់តែខ្លាំងឡើង រហូតដល់ឈ្មោះ [redacted] ឈាវ៉ាន់, ឈ្មោះ [redacted] ឆារី និងឈ្មោះ [redacted] រុំ បានទាន់ដាក់ឈ្មោះ [redacted] ធី និងប្រពន្ធត្រូវក្បាល និងចង្កេះ។ ចំណែកឯឈ្មោះ [redacted] ធី និងកូនឈ្មោះ [redacted] ផល្លា បានយកកូនកាំបិតចុងស្រួចកាប់ទៅលើឈ្មោះ [redacted] ឈាវ៉ាន់, ឈ្មោះ [redacted] ឆារី វិញបណ្តាលឱ្យឈ្មោះ [redacted] ឈាវ៉ាន់ របួសកែងដៃឆ្វេង លើដោះស្តាំ ប្រអប់ដៃឆ្វេង ហើយឈ្មោះ [redacted] ឆារី របួសខ្នងដៃត្រង់ម្រាមទាំង ៤ បណ្តាលឱ្យដាច់ម្រាមដៃនាងហូរឈាមយ៉ាងច្រើន ហើយភាគីទាំងពីរក៏ប្រតាយប្រតប់គ្នាដណ្តើមយកកាំបិតកាប់គ្នាទៅវិញទៅមក បណ្តាលឱ្យរងរបួសធ្ងន់ធ្ងរទាំងសងខាង។

សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៤៧ "ម" ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅនេះ ៖

១.ផ្តន្ទាទោសជនជាប់ចោទ ៖

ក.ឈ្មោះ [redacted] ធី ភេទប្រុស អាយុ ៥៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា។

Scanned with CamScanner

ខ.ឈ្មោះ [redacted] ផល្លា ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា។

ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចភូមិ ១ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ១០៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

គ.ឈ្មោះ [redacted] ឈាន់ ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៣ (បី) ឆ្នាំ។

ឃ.ឈ្មោះ [redacted] ធារី ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៣ (បី) ឆ្នាំ។

ង.ឈ្មោះ [redacted] រ៉ុ ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៣ (បី) ឆ្នាំ។

ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចភូមិ ១ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា ២១៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

២.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ឈាន់, ឈ្មោះ [redacted] ធារី និងឈ្មោះ [redacted] រ៉ុ រួមគ្នាសងសំណងការខូចខាតនិងជំងឺចិត្តចំនួន ១២,០០០,០០០ (ដប់ពីរលាន)រៀល ទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធី, ឈ្មោះ [redacted] ផល្លា និងចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ឈាន់, ឈ្មោះ [redacted] ធារី និងឈ្មោះ [redacted] រ៉ុ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ ។

រក្សាសិទ្ធិប្ដឹងទាស់ ឬឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

សាលក្រមនេះត្រូវបានឈ្មោះ [redacted] ធារី ប្ដឹងទាស់តាមរយៈបណ្ដឹងលេខ ៥៩ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៧ "ម" ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី ១.ឃ និងទី ២ នៃសេចក្ដីសម្រេច។

សាលក្រមនេះត្រូវបានឈ្មោះ [redacted] រ៉ុ ប្ដឹងទាស់តាមរយៈបណ្ដឹងលេខ ៦០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៧ "ម" ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី ១.ង និងទី ២ នៃសេចក្ដីសម្រេច។



Scanned with CamScanner

សាលក្រមនេះត្រូវបានឈ្មោះ [redacted] ឈាក់ន់ ប្តឹងទាស់តាមរយៈបណ្តឹងលេខ ៦១ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៧ "ម" ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី ១.គ និងទី ២ នៃសេចក្តីសម្រេច។

សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៥៨៧ "ម" ក.ព.ព្រ.ទ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៤ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ទទួលបណ្តឹងទាស់ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ឈាក់ន់ ភេទប្រុស អាយុ ៣៩ឆ្នាំ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២.បណ្តឹងទាស់ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ធារី ភេទប្រុស អាយុ ២៧ឆ្នាំ និងឈ្មោះ [redacted] រ៉ុ ភេទប្រុស អាយុ ៣៤ ឆ្នាំ ទុកជាឯកសារឥតបានការតាមមាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៧ "ម" ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធី, ឈ្មោះ [redacted] ផល្លា, ឈ្មោះ [redacted] ឈាក់ន់, មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុជាតា ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ចាន់ ហៀង ចាត់ទុកចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធារី, ឈ្មោះ [redacted] រ៉ុ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៤។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

សាលក្រមព្រហ្មទណ្ឌនេះត្រូវបានឈ្មោះ [redacted] ឈាក់ន់ និងឈ្មោះ [redacted] ធារី ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៦៥៧ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៨៧ "ម" ក.ព.ព្រ.ទ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៤ របស់សាលាសាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

សាលក្រមព្រហ្មទណ្ឌនេះត្រូវបានឈ្មោះ [redacted] រ៉ុ ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៦៦១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៨៧ "ម" ក.ព.ព្រ.ទ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

សាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៥៨ "ក្រ IV ទល" ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១. ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៦៥៧ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] ឈាក់ន់ និងឈ្មោះ [redacted] ធារី និងពាក្យបណ្តឹងឧទ្ធរណ៍លេខ ៦៦១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] រ៉ុ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ខ្លះ ។



Scanned with CamScanner

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៨៧ "ម" ក.ព.ព្រ.ទ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៧ "ម" ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងត្រង់ចំណុចទី១ (គ) (ឃ) (ង) នៃសេចសម្រេចត្រង់ការផ្តន្ទាទោសឈ្មោះ [redacted] ឈាក់ន់, ឈ្មោះ [redacted] ឆាវី, ឈ្មោះ [redacted] រ៉ុ ដាក់ពន្ធនាគារកំណត់ចំនួន ០៣ (បី) ឆ្នាំ ត្រូវកែប្រែមកជាផ្តន្ទាទោសលើឈ្មោះ [redacted] ឈាក់ន់, ឈ្មោះ [redacted] ឆាវី, ឈ្មោះ [redacted] រ៉ុ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ ដោយត្រូវអនុវត្តទោសគុកយៈពេល ០៥ (ប្រាំ)ខែ ទោសសល់ពីនេះព្យួរធម្មតា តាមបញ្ញត្តិមាត្រា ២១៨ មាត្រា ១០៤ មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ និងត្រង់ចំណុចទី ២ នៃសេចក្តីសម្រេចត្រង់បង្គាប់ឱ្យឈ្មោះ [redacted] ឈាក់ន់, ឈ្មោះ [redacted] ឆាវី, ឈ្មោះ [redacted] រ៉ុ រួមគ្នាសងសំណងការខូចខាត និងជម្ងឺចិត្តចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង ត្រូវកែប្រែមកជាបង្គាប់ឱ្យឈ្មោះ [redacted] ឈាក់ន់, ឈ្មោះ [redacted] ឆាវី, ឈ្មោះ [redacted] រ៉ុ រួមគ្នាសងសំណងថ្លៃព្យាបាលរបួសសរុបចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល និងជម្ងឺចិត្តចំនួន ២.០០០.០០០ (ពីរលាន) រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅសាលសវនាការនៃសាលាឧទ្ធរណ៍នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ចំពោះមុខឈ្មោះ [redacted] ឈាក់ន់, ឈ្មោះ [redacted] ឆាវី, ឈ្មោះ [redacted] ផល្លា, ឈ្មោះ [redacted] ជី កំបាំងមុខឈ្មោះ [redacted] រ៉ុ ។

បើកផ្លូវប្តឹងទាស់ និងប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សាលដីកានេះ ត្រូវបានជនជាប់ចោទឈ្មោះ [redacted] ឈាក់ន់ និងឈ្មោះ [redacted] ឆាវី ប្តឹងសាទុក្ខតាមបណ្តឹងលេខ ២៨៤ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូលនៃសាលដីកា។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្តីសន្និដ្ឋានថា ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ ដែលតម្កល់សាលក្រមព្រហ្មទណ្ឌ របស់សាលាដំបូងទុកជាបានការដដែល ដោយគ្រាន់តែប្រែកំរិតទណ្ឌកម្ម លើជនជាប់ចោទជាម្ចាស់បណ្តឹងសាទុក្ខទាំង២នាក់ ដាក់ពន្ធនាគារក្នុងម្នាក់ៗ ពី ៣ឆ្នាំមក ២ឆ្នាំវិញ ដោយអនុវត្តទោសគុក ៥ខែ ទោសនៅសល់ព្យួរ និងកែប្រែសំណងជម្ងឺចិត្តពី ១២លានរៀលមកជាសងថ្លៃព្យាបាលរបួស ៦លានរៀល និងសងជម្ងឺចិត្តចំនួន ២លានរៀល គឺមានសំអាងហេតុ និងកស្តុតាងត្រឹមត្រូវតាមច្បាប់ ព្រោះថា៖ តាមចម្លើយរបស់ភាគីជនជាប់ចោទ ជនរងគ្រោះ និងសាក្សី បង្ហាញឱ្យឃើញថា ជនជាប់ចោទ ជាម្ចាស់បណ្តឹងសាទុក្ខ ពិតជាបានប្រព្រឹត្តអំពីល្មើសដូចបទចោទ ពិតមែន ដូចមានក្នុងសំអាងហេតុចាប់ពីចំណុចទី២ ដល់ចំណុចទី១១ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់។ ដូច្នេះ



Scanned with CamScanner

តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច តម្កល់សាលដីកាព្រហ្មទណ្ឌ ៥៨ "ក្រ IV ទល" ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

-ជនជាប់ចោទឈ្មោះ [redacted] ឈាវ៉ាន់ បានឆ្លើយថា ខ្លួនជាជនរងគ្រោះត្រូវគេកាប់ខ្លួនហើយ គេប្តឹងខ្លួនទៀត។ ខ្លួនសុំឱ្យតុលាការកំពូលលើកលែងការចោទប្រកាន់ក្នុងរឿងក្តីនេះ និងសុំកុំឱ្យមានសំណងអ្វីទៀត។

-ជនជាប់ចោទឈ្មោះ [redacted] ធារី បានឆ្លើយថា ខ្លួនជាអ្នករងគ្រោះ គេបានកាប់ខ្លួន ដាច់ម្រាមដៃនាងខាងស្តាំហើយ គេប្តឹងខ្លួនទៀត។ ខ្លួនសុំឱ្យតុលាការកំពូលលើកលែងការចោទប្រកាន់មកលើខ្លួន និងសុំកុំឱ្យមានសំណងអ្វីទៀត។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង បានឆ្លើយថា ខ្លួនសុំឱ្យតុលាការកំពូលតម្កល់សាលក្រមរបស់សាលាដំបូង និងសាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការដដែល។

## តុលាការកំពូល

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៨៤ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ឈាវ៉ាន់ និងឈ្មោះ [redacted] ធារី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងក្តីនេះមកជំនុំជម្រះបានតាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧, ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានីភ្នំពេញលេខ ៥៨ "ក្រ IV ទល" ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ទុកជាបានការ ដែលបានប្រកាសពិរុទ្ធភាព និងប្រកាសទោសលើជនជាប់ចោទឈ្មោះ [redacted] ឈាវ៉ាន់ និងឈ្មោះ [redacted] ធារី ពីបទហឹង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមបទប្បញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ នោះជាការត្រឹមត្រូវហើយ ពីព្រោះថាតាមចម្លើយបំភ្លឺរបស់សាក្សីដែលបានឃើញហេតុការណ៍ដោយផ្ទាល់ គឺឈ្មោះ [redacted] ស្រីពៅ និងឈ្មោះ [redacted] រតនៈ ដែលជាអ្នករស់នៅជិតខាងគូជម្លោះ ព្រមទាំងរូបថតបង្ហាញពីស្លាកស្នាមរបួសលើរាងកាយជនរងគ្រោះឈ្មោះ [redacted] ធី បង្ហាញឱ្យឃើញថាឈ្មោះ [redacted] ធី ត្រូវរបួសក្បាលត្រូវបានដេរចំនួន ៤ ថ្នេរ ស្នាមធូតលើថ្ងាស,ឈ្មោះ [redacted] ផល្លា ត្រូវរបួសម្រាមដៃ ត្រូវដេរចំនួន ២ ថ្នេរ និងខ្នងចំនួន ១៦ ថ្នេរ និងឈ្មោះ [redacted] ហៀង មានរបួសក្រោមរង្វង់ភ្នែកខាងស្តាំ និងខ្នងផងនោះ។ កស្តុតាងទាំងនេះវា



Scanned with CamScanner

មានលក្ខណៈស៊ីចង្វាក់គ្នាជាមួយនឹងចម្លើយអះអាងរបស់ជនរងគ្រោះម្នាក់ៗ ដែលហេតុការណ៍ទាំងអស់នេះ គឺជាភស្តុតាងបញ្ជាក់បង្ហាញយ៉ាងជាក់ច្បាស់ថាជនជាប់ចោទឈ្មោះ [redacted] ឈាវ៉ាន់ និងឈ្មោះ [redacted] ធារី ពិតជាបានវាយជនរងគ្រោះឈ្មោះ [redacted] ហៀង នៅច្រកចូល ត្រូវដួលនៅនឹងកន្លែង និងបានចូលវាយឈ្មោះ [redacted] ធី ត្រូវដួលនៅក្នុងផ្ទះ ព្រមទាំងបានយកកាំបិតប៉ាំងតោមកកាប់ឈ្មោះ [redacted] ផល្លា និង ប្រាក់ ធី បណ្ដាលឱ្យមានរបួសឈាមហូរជោគខ្លួន នៅថ្ងៃកើតហេតុប្រាកដមែន។ ដោយហេតុថាអំពើហិង្សាដែលបានប្រព្រឹត្តដោយជនជាប់ចោទទាំង២ នាក់នេះបានប្រើកាំបិតប៉ាំងតោជាអាវុធនិងមានមនុស្សច្រើននាក់បានចូលរួមប្រព្រឹត្តក្នុងឋានៈជាសហចារី។ អំពើហិង្សាដែលបានប្រព្រឹត្តនេះរបស់ជនជាប់ចោទទាំង ២ នាក់ គឺជាអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដូចមានបញ្ញត្តនៅត្រង់ចំណុចទី២ និងទី៣ នៃមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។ រីឯការផ្តន្ទាទោសលើជនជាប់ចោទទាំង ២ នាក់នេះវិញ ស្ថិតក្នុងកម្រិតអប្បបរមានៃទោសប្បញ្ញត្តិក្នុងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ គឺទោសដាក់ពន្ធនាគារកំណត់តែ ២ ឆ្នាំ ដោយឱ្យអនុវត្តទោសជាប់ពន្ធនាគារកំណត់តែ ០៥ ខែ និងទោសនៅសល់ឱ្យអនុវត្តទោសព្យួរធម្មតាទៀតផងនោះ គឺមានចរិតលក្ខណៈជាការផ្ដល់នូវស្ថានសម្រាលទោសឱ្យដល់ជនជាប់ចោទទាំង ២ នាក់នេះ ជាពិសេសហើយ។

៣-យល់ឃើញថា សំណូមពររបស់ជនជាប់ចោទនាពេលសវនាការថា សុំឱ្យតុលាការសម្រេចសេចក្ដីឱ្យខ្លួនបានរួចខ្លួនពីបទចោទប្រកាន់ និងសុំរួចផុតពីការទទួលខុសត្រូវខាងសំណងរដ្ឋប្បវេណី ដោយសារខ្លួន គឺជាជនរងគ្រោះដែរនោះ តុលាការកំពូលពិចារណាថា គឺជាសំណូមពរមិនមានមូលដ្ឋានសមស្របតាមផ្លូវច្បាប់ឡើយ។ មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទទាំង ២ នាក់ ពីបទបានចោទប្រកាន់ ដូច្នេះជាផលវិបាកជនជាប់ចោទទាំង ២ នាក់ គឺត្រូវតែទទួលខុសត្រូវជួសជុលព្យសនកម្មដែលពួកគាត់បានបង្កឡើង យោងតាមបទប្បញ្ញត្តិមាត្រា ១៤ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-យល់ឃើញថា បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ [redacted] ឈាវ៉ាន់ និង [redacted] ធារី មិនមានមូលហេតុ នៃបណ្ដឹងសាទុក្ខសមស្របនឹងបទប្បញ្ញត្តិណាមួយ ចំណុចណាមួយឬច្រើន តាមបទប្បញ្ញត្តិមាត្រា ៤១៩ នៃក្រម នីតិវិធីព្រហ្មទណ្ឌនោះទេ។

៥-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥៨ "ក្រIV ទល" ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្ដីមកនេះត្រឹមត្រូវតាមគតិច្បាប់ហើយ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-បដិសេធបណ្ដឹងសាទុក្ខលេខ ២៨៤ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ឈាវ៉ាន់ និងឈ្មោះ [redacted] ធារី ។

Scanned with CamScanner

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៩៨ "ក្រ៧ ទល" ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដដែល។

*សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃសុក្រ ទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសនាសនៅការជាសាធារណៈ នៅថ្ងៃសុក្រ ទី០៦ ខែមីនា ឆ្នាំ២០២០៕*

Scanned with CamScanner